ក

មាតិកា

I. ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៨-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៤៨៤ ស្ដីពីការផ្ទេរក្របខ័ណ្ឌលោក **ជួប សុគន្ធី** អនុមន្ត្រី ថ្នាក់លេខ ១៣ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្ដីការគណៈរដ្ឋមន្ត្រី ទៅជាអនុមន្ត្រី ថ្នាក់លេខ ១៣ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ៧៦០៤

០៨-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៤៨៥ ស្ដីពីការលុបឈ្មោះឯកឧត្ដម **ខូន ផនស៊ីផុន** ឧត្ដមមន្ត្រី ថ្នាក់លេខ ១ ចេញពីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៃទីស្ដីការគណៈរដ្ឋមន្ត្រី ដោយមូលហេតុ ទទួលមរណភាព ៧៦០៥

០៨-១២-២០០៥ -ព្រះរាជក្រឹត្យនស/រកត/១២០៥/៤៨៦ ស្ដីពីការប្រោសព្រះរាជទានគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ១១រូប នៃក្រសួងមហាផ្ទៃ ៧៦០៦

០៨-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៤៨៨ ស្ដីពីការតែងតាំងឯកឧត្ដម **សៅ ជីវ័ន្ត** ជាសមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច និងវប្បធម៌ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៧៦០៧

០៨-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៤៨៩ ស្ដីពី ត្រូវបានធ្វើសមាហរណកម្មទៅក្នុងក្របខ័ណ្ឌឧត្ដមមន្ត្រីថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នូវមន្ត្រីរាជការស៊ីវិល ចំនួន ០៤ រូប ៧៦០៨

០៨-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៤៩០ ស្ដីពីការតែងតាំងលោក **ម៉ូ គឹមឆេង** ជា **ឧកញ៉ា** ៧៦០៩

០៨-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៤៩១ ស្ដីពីការតែងតាំងព្រះអង្គម្ចាស់ក្សត្រិយ៍ **ស៊ីសុវត្ថិ កល្យាណទេវី** ជាលេខាធិការផ្ទាល់ **ព្រះមហាក្សត្រ** មានឋានៈស្មើ **រដ្ឋលេខាធិការ** ៧៦១០

០៨-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៤៩២ ស្ដីពីការតែងតាំងឯកឧត្ដម **ចែម សទ្ធា** ជាទីប្រឹក្សាសម្ដេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភាទទួលបន្ទុកការងារប្រៃសណីយ៍និងទូរគមនាគមន៍ មានឋានៈស្មើរដ្ឋលេខាធិការបន្ថែមលើមុខងារបច្ចុប្បន្នដោយពុំទទួលប្រាក់បៀវត្ស ៧៦១១

០៨-១២-២០០៥ -ព្រះរាជក្រឹត្យនស/រកត/១២០៥/៤៩៣ស្តីពីការតែងតាំងលោក**គីម ហេង** ជា **ឧកញ៉ា** ៧៦១២

០៨-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៤៩៤ ស្តីពីការតម្លើងឋានៈឯកឧត្តម **ម៉ៅ ញ៉ៅ** ជាទីប្រឹក្សាសម្តេច **ហេង សំរិន** អនុប្រធានទី ១ នៃរដ្ឋសភានីតិកាលទី ៣ ទទួលបន្ទុកសន្តិសុខ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ៧៦១៣

១២-១២-២០០៥ -ព្រះរាជក្រឹត្យនស/រកត/១២០៥/៤៩៥ ស្តីពីការប្រោសព្រះរាជទានគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** ជូនថ្នាក់ដឹកនាំ និងសមាជិក នៃគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ចំនួន ១៣ រូប ៧៦១៤

១២-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៤៩៧ ស្តីពីការប្រោសព្រះរាជទានចំពោះឯកឧត្តមឧត្តមសេនីយ៍ឯក **អ៊ុន ជ៉េន** នូវគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ៧៦១៥

១២-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៤៩៨ ស្តីពីការតម្លើងឋានន្តរសក្តិជូនដល់នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៧៦១៦

១២-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥០០ ស្តីពីការប្រោសព្រះរាជទានជាកិច្ចបច្ឆាមរណៈចំពោះសពឯកឧត្តម **ណុប លាន** នូវគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ៧៦១៧

១២-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥០១ ស្តីពីការតែងតាំងឯកឧត្តម **តុង សេង** ជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារវិនិយោគ មានឋានៈស្មើ **រដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស ៧៦១៨

១៩-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥០៦ ស្តីពីការផ្ទេរក្របខ័ណ្ឌលោក **យូ ម៉ាសិទ្ធិ** អនុមន្ត្រីថ្នាក់លេខ ១៣ នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ទៅជាអនុមន្ត្រីថ្នាក់លេខ ១៣ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៅក្រសួងកិច្ចការនារី ៧៦១៩

II_រាជរដ្ឋាភិបាល

១_អនុក្រឹត្យ

១៦-១២-២០០៥ -អនុក្រឹត្យលេខ ១៤១ អនក្រ.បក ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ៧៦២០

១៩-១២-២០០៥	-អនុក្រឹត្យលេខ ១៨២ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា	៧៦២២
១៩-១២-២០០៥	-អនុក្រឹត្យលេខ ១៨៣ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា	៧៦២៤
២១-១២-២០០៥	-អនុក្រឹត្យលេខ ១៨៤ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា	៧៦២៦
២៣-១២-២០០៥	-អនុក្រឹត្យលេខ ១៨៥ អនក្រ.បក ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងផ្លាកសញ្ញាសំគាល់របស់ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និង បង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល "	៧៦២៨
១៦-១២-២០០៥	-អនុក្រឹត្យលេខ ៨៨៧ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូននាយនគរបាលជាតិ	៧៦៤៣
១៦-១២-២០០៥	-អនុក្រឹត្យលេខ ៨៨៨ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ	៧៦៤៤
១៩-១២-២០០៥	-អនុក្រឹត្យលេខ ៨៨៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៧៦៤៥
១៩-១២-២០០៥	-អនុក្រឹត្យលេខ ៨៩០ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	៧៦៤៦
១៩-១២-២០០៥	-អនុក្រឹត្យលេខ ៨៩១ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	៧៦៤៧
១៩-១២-២០០៥	-អនុក្រឹត្យលេខ ៨៩២ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី	៧៦៤៨
១៩-១២-២០០៥	-អនុក្រឹត្យលេខ ៨៩៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	៧៦៤៩
២០-១២-២០០៥	-អនុក្រឹត្យលេខ ៨៩៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៧៦៥០
២០-១២-២០០៥	-អនុក្រឹត្យលេខ ៨៩៥ អនក្រ.តត ស្តីពីការជូនមេដាយការងារ	៧៦៥១
២០-១២-២០០៥	-អនុក្រឹត្យលេខ ៨៩៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	៧៦៥២
២០-១២-២០០៥	-អនុក្រឹត្យលេខ ៨៩៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	៧៦៥៣
២១-១២-២០០៥	-អនុក្រឹត្យលេខ ៨៩៨ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ	៧៦៥៤
២១-១២-២០០៥	-អនុក្រឹត្យលេខ ៨៩៩ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ	៧៦៥៥
២១-១២-២០០៥	-អនុក្រឹត្យលេខ ៩០០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	៧៦៥៦
២១-១២-២០០៥	-អនុក្រឹត្យលេខ ៩០១ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី	៧៦៥៧
២១-១២-២០០៥	-អនុក្រឹត្យលេខ ៩០២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៧៦៥៨
២១-១២-២០០៥	-អនុក្រឹត្យលេខ ៩០៣ អនក្រ.តត ស្តីពីការតែងតាំងមុខតំណែងនាយនគរបាលជាតិ	៧៦៥៩
២១-១២-២០០៥	-អនុក្រឹត្យលេខ ៩០៤ អនក្រ.តត ស្តីពីការអនុវត្តវិន័យនាយនគរបាលជាតិ	៧៦៦០
២១-១២-២០០៥	-អនុក្រឹត្យលេខ ៩០៥ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី	៧៦៦២
២១-១២-២០០៥	-អនុក្រឹត្យលេខ ៩០៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៧៦៦៣
២២-១២-២០០៥	-អនុក្រឹត្យលេខ ៩០៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៧៦៦៤

III-ការងារបណ្ដាក្រសួង

១-ទីស្ដីការគណៈរដ្ឋមន្ត្រី

២១-១២-២០០៥ -ប្រកាសលេខ ១៥៦ ប្រ.ក ស្ដីពី ការបង្កើតលេខាធិការដ្ឋានមេធាវីរាជរដ្ឋាភិបាល ៧៦៦៧

២-ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២២-១២-២០០៥ -ប្រកាសលេខ ៩៧១ សហវ.ប្រក ស្ដីពីការបង្កើត លេខាធិការដ្ឋាននៃគណៈកម្មាធិការគណទានសំរាប់អភិវឌ្ឍន៍ជនបទ ៧៦៦៩

៣-ទីស្ដីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

២០-១២-២០០៥ -ប្រកាសលេខ ១៨៣៤ អយក.ប្រក ស្ដីពីការបើកអនុវិទ្យាល័យ «**អធិបតី**» ស្ថិតនៅក្នុងឃុំ ត្រីញ័រ ស្រុក ពួក ខេត្ត សៀមរាប ៧៦៧២

២០-១២-២០០៥ -ប្រកាសលេខ ១៨៣៥ អយក.ប្រក ស្ដីពីការបើកអនុវិទ្យាល័យ «**ពពេល**» ស្ថិតនៅក្នុងឃុំ ពពេល ស្រុក សូទ្រនិគម ខេត្ត សៀមរាប ៧៦៧៣

២០-១២-២០០៥ -ប្រកាសលេខ ១៨៣៦ អយក.ប្រក ស្ដីពីការបើកអនុវិទ្យាល័យ «**ពង្រ**» ស្ថិតនៅក្នុងឃុំ ពង្រក្រោម ស្រុក ជីក្រែង ខេត្ត សៀមរាប ៧៦៧៤

២០-១២-២០០៥ -ប្រកាសលេខ ១៨៣៧ អយក.ប្រក ស្ដីពីការបើកអនុវិទ្យាល័យ «**ឧត្តមទួលបី**» ស្ថិតនៅក្នុងឃុំ រាយប៉ាយ ស្រុក កងមាស ខេត្ត កំពង់ចាម ៧៦៧៥

២០-១២-២០០៥ -ប្រកាសលេខ ១៨៤៨ អយក.ប្រក ស្ដីពីការប្ដូរឈ្មោះអនុវិទ្យាល័យ «**ត្រពាំងក្រសាំង**» ទៅជា អនុវិទ្យាល័យ «**ហ៊ុនសែន ប៊ុនរ៉ានី អរុណវតី**» ស្ថិតនៅក្នុងសង្កាត់ ត្រពាំងក្រសាំង ខ័ណ្ឌ ដង្កោ ក្រុងភ្នំពេញ ៧៦៧៦

២១-១២-២០០៥ -ប្រកាសលេខ ១៨៤៩ អយក.ប្រក ស្ដីពីការបើកអនុវិទ្យាល័យ «**អង្គុញ**» ស្ថិតនៅក្នុងឃុំ អង្គុញ ស្រុក ទ្រាំង ខេត្ត តាកែវ ៧៦៧៧

២១-១២-២០០៥ -ប្រកាសលេខ ១៨៥០ អយក.ប្រក ស្ដីពីការបើកអនុវិទ្យាល័យ «**វត្តបារាយណ៍ វិហារពីរ**» ស្ថិតនៅក្នុងឃុំ ព្រៃស្លឹក ស្រុក ទ្រាំង ខេត្ត តាកែវ ៧៦៧៨

២១-១២-២០០៥ -ប្រកាសលេខ ១៨៥១ អយក.ប្រក ស្ដីពីការបើកអនុវិទ្យាល័យ «**ចំប៉ាលើក**» ស្ថិតនៅក្នុងឃុំ តាភេម ស្រុក ត្រាំកក់ ខេត្ត តាកែវ ៧៦៧៩

២១-១២-២០០៥ -ប្រកាសលេខ ១៨៥២ អយក.ប្រក ស្ដីពីការបើកអនុវិទ្យាល័យ «**ព្រៃយុថ្កា**» ស្ថិតនៅក្នុងឃុំ ព្រៃយុថ្កា ស្រុក កោះអណ្ដែត ខេត្ត តាកែវ ៧៦៨០

២១-១២-២០០៥ -ប្រកាសលេខ ១៨៥៣ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ «**អណ្តូងសិរិត**» ស្ថិតនៅក្នុងឃុំ ផ្លាប្រជុំ ស្រុក កោះអណ្តែត ខេត្ត តាកែវ ៧៦៨១

២១-១២-២០០៥ -ប្រកាសលេខ ១៨៥៤ អយក.ប្រក ស្តីពីការពង្រីកអនុវិទ្យាល័យ «**ប៊ុន រ៉ានី ហ៊ុន សែន ភ្នំជីសូរ**» ទៅជាវិទ្យាល័យ «**ប៊ុន រ៉ានី ហ៊ុន សែន ភ្នំជីសូរ**» ស្ថិតនៅក្នុងឃុំរវៀង ស្រុក សំរោង ខេត្ត តាកែវ ៧៦៨២

២១-១២-២០០៥ -ប្រកាសលេខ ១៨៥៥ អយក.ប្រក ស្តីពីការពង្រីកអនុវិទ្យាល័យ «**ច័ន្ទក្រឹស្នា**» ទៅជាវិទ្យាល័យ «**ច័ន្ទក្រឹស្នា**» ស្ថិតនៅក្នុងឃុំច្រេស ស្រុក មេសាង ខេត្ត ព្រៃវែង ៧៦៨៣

២១-១២-២០០៥ -ប្រកាសលេខ ១៨៥៦ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ «**គោកគង់កើត**» ស្ថិតនៅក្នុងឃុំ គោកគង់កើត ស្រុក កញ្ជ្រៀច ខេត្ត ព្រៃវែង ៧៦៨៤

២១-១២-២០០៥ -ប្រកាសលេខ ១៨៥៧ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ «**ព្រះឈរ**» ស្ថិតនៅក្នុងឃុំ ព្រះឈរ ស្រុក កំពង់ត្របែក ខេត្ត ព្រៃវែង ៧៦៨៥

២១-១២-២០០៥ -ប្រកាសលេខ ១៨៥៨ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ «**កំពង់ត្របែក**» ស្ថិតនៅក្នុងឃុំ កំពង់ត្របែក ស្រុក កំពង់ត្របែក ខេត្ត ព្រៃវែង ៧៦៨៦

២១-១២-២០០៥ -ប្រកាសលេខ ១៨៥៩ អយក.ប្រក ស្តីពីការបើកសាលារៀនចំណេះទូទៅឯកជន «**មជ្ឈមណ្ឌលចំណេះទូទៅអន្តរទ្វីប**» ស្ថិតនៅក្នុងសង្កាត់លេខ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ៧៦៨៧

២១-១២-២០០៥ -ប្រកាសលេខ ១៨៦០ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ «**សែនសុខ**» ស្ថិតនៅក្នុងឃុំ សែនសុខ ស្រុក ក្រឡាញ់ ខេត្ត សៀមរាប ៧៦៨៩

២១-១២-២០០៥ -ប្រកាសលេខ ១៨៦១ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ «**អន្លង់អក**» ស្ថិតនៅក្នុងឃុំ សូរគង ស្រុក កងមាស ខេត្ត កំពង់ចាម ៧៦៩០

២១-១២-២០០៥ -ប្រកាសលេខ ១៨៦២ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ «**ព្រៃចក្រី**» ស្ថិតនៅក្នុងឃុំ អូរស្វាយ ស្រុក កំពង់សៀម ខេត្ត កំពង់ចាម ៧៦៩១

៤_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២០-១២-២០០៥ -ប្រកាសលេខ ៣១៧ MOC/SM 2005 ស្តីពីស្ថានភាពរោងចក្រកាត់ដេរ UNITED ARTS GARMENT FACTORY LTD. ៧៦៩២

20-12-2005 -PRAKAS N° 317 MOC/SM 2005 On The Status of UNITED ARTS GARMENT FACTORY LTD.in Cambodia ៧៦៩៤

២៤-១១-២០០៥ -លិខិតលេខ ២៦៣៤ ពណ.នគក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ហ្គ្រេត ស្តារ ស៊ីធីស** ៧៦៩៦

២៤-១១-២០០៥ -លិខិតលេខ ២៦៣៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ស្ទើរអង្គរ ព្រីនធីង ហៅស៍ ៧៦៩៨

២៥-១១-២០០៥ -លិខិតលេខ ២៦៣៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ស៊ី.ធី. មិត្តភាពប៉ៃលិន ៧៧០០

២៥-១១-២០០៥ -លិខិតលេខ ២៦៣៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ឌី អិន អេ អេណើជី ខមភេនី ៧៧០២

២៥-១១-២០០៥ -លិខិតលេខ ២៦៣៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
អ័ហ្គានិក ប្រូដាក់ អិចផត ៧៧០៤

២៥-១១-២០០៥ -លិខិតលេខ ២៦៣៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
អេស៊ា ឡាយអិន គ្រុប ៧៧០៦

២៥-១១-២០០៥ -លិខិតលេខ ២៦៤០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ឡៀសាន អភិវឌ្ឍន៍ ៧៧០៨

២៥-១១-២០០៥ -លិខិតលេខ ២៦៤១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
សេគុង អភិវឌ្ឍន៍ ៧៧១០

២៥-១១-២០០៥ -លិខិតលេខ ២៦៤២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
អានិទេព អាហារ៉ណា នីហារ៉ណា & សំណង់ ៧៧១២

២៥-១១-២០០៥ -លិខិតលេខ ២៦៤៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ស៊ី ធី អិម ខេ ត្រេឌីង ៧៧១៤

២៥-១១-២០០៥ -លិខិតលេខ ២៦៥២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ធី.អេ.អ៊ី.អេ ៧៧១៦

២៥-១១-២០០៥ -លិខិតលេខ ២៦៥៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
គង់ លួន ហ៊ីង ៧៧១៨

២៥-១១-២០០៥ -លិខិតលេខ ២៦៥៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
មីន មានជ័យ អ៊ីមផត អិចផត ៧៧២០

២៥-១១-២០០៥ -លិខិតលេខ ២៦៦៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ផ្ទូថុន ល័ញ ខូ អិលធីឌី ៧៧២២

២៥-១១-២០០៥ -លិខិតលេខ ២៦៦៦ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
មេគង្គ ព្រីនធីង ហៅស៍ ៧៧២៤

២៥-១១-២០០៥ -លិខិតលេខ ២៦៦៧ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ជីនម៉ីយ៉ុង ហ្គាមេន ឌីវើឡុបមេន ខប ៧៧២៦

២៨-១១-២០០៥ -លិខិតលេខ ២៦៧១ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
អេស អាយ អេស គ្រុប ភីធីអ៊ី អិលធីឌី ៧៧២៧

២៨-១១-២០០៥ -លិខិតលេខ ២៦៧២ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ខេ អិន អិន (ខេមបូឌា) ៧៧២៩

២៨-១១-២០០៥ -លិខិតលេខ ២៦៧៧ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
អ៊ី ថាច់ អេហ្វ មេគង្គ ៧៧៣១

២៨-១១-២០០៥ -លិខិតលេខ ២៦៧៨ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
អាល់ហ្វា ខបភើរេត សឺវិស ៧៧៣៣

២៩-១១-២០០៥ -លិខិតលេខ ២៦៧៩ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
អ៊ីនត្រាប៊ីហ្ស ៧៧៣៥

៣០-១១-២០០៥ -លិខិតលេខ ២៦៨៥ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
សានទូ (ខេមបូឌា) ៧៧៣៧

៣០-១១-២០០៥ -លិខិតលេខ ២៦៨៦ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
កំសាន្តថ្មី ៦៦៦ ៧៧៣៨

៣០-១១-២០០៥ -លិខិតលេខ ២៦៨៧ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ខេ អេច អិម អិន ខេបភើរេសិន (ខេមបូឌា) ៧៧៤០

៣០-១១-២០០៥ -លិខិតលេខ ២៦៨៨ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ប្រាសាទ បូរាណ ធូរ ៧៧៤២

៣០-១១-២០០៥ -លិខិតលេខ ២៦៨៩ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ហ្វីស អ៊ីសធើន ត្រេនស្ព័ត ៧៧៤៤

៣០-១១-២០០៥ -លិខិតលេខ ២៦៩០ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ធ្លូ វ៉ែអ៊ែរ ៧៧៤៦

៣០-១១-២០០៥ -លិខិតលេខ ២៦៩១ ពណ.នគក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ជេ ប៊ី អិន ជី, ស្ទីល ៧៧៤៨

០១-១២-២០០៥ -លិខិតលេខ ២៦៩៩ ពណ.នគក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
យុន ហ្វុង ប៊ីលឌីង មេឌៀរៀល ខមភេនី អិលធីឌី ៧៧៥០

០១-១២-២០០៥ -លិខិតលេខ ២៧០៣ ពណ.នគក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
តិស ភ្លូរី (ខេមបូឌា) មេនូហ្វេកឈ័រីង ៧៧៥២

០៦-១២-២០០៥ -លិខិតលេខ ២៧១០ ពណ.នគក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ហុង វណ្ណានីន ៧៧៥៣

០៦-១២-២០០៥ -លិខិតលេខ ២៧១៥ ពណ.នគក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ដាប់បែលយូ.ជេ. អ៊ិនធើណេសិនណល (ខេមបូឌា) សាយអិនស៍ ខូអបតើរេត ៧៧៥៥

០៦-១២-២០០៥ -លិខិតលេខ ២៧១៦ ពណ.នគក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ជា ចំណាន ស៊ី.អិម.តី ខូអិលធីឌី ៧៧៥៧

០៦-១២-២០០៥ -លិខិតលេខ ២៧១៨ ពណ.នគក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ខ្មែរឧប្ប ៧៧៥៩

០៦-១២-២០០៥ -លិខិតលេខ ២៧២២ ពណ.នគក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
លីឌីយ៉ា លុយឌីច (ខេមបូឌា) ៧៧៦១

០៦-១២-២០០៥ -លិខិតលេខ ២៧២៥ ពណ.នគក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
វ៉េនធី ខូ អិលធីឌី ៧៧៦៣

០៦-១២-២០០៥ -លិខិតលេខ ២៧២៦ ពណ.នគក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ស៊ី.អាយ.ស៊ី.អេស (ខេមបូឌា អ៊ិនធើណេសិនណល ខនសាល់ធីង សឺវីស) ៧៧៦៥

០៦-១២-២០០៥ -លិខិតលេខ ២៧២៧ ពណ.នគក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ហ្គូលដេន ប្រូហ្វីត (ខេមបូឌា) ហ្គាមេន ៧៧៦៧

០៧-១២-២០០៥ -លិខិតលេខ ២៧៣១ ពណ.នគក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ស៊ី អ៊ី ឌី ខមភេនី ៧៧៦៨

២៩-១១-២០០៥ -លិខិតលេខ ២៦៨៣ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
អេស វណ្ណារី ខូអិលធីឌី ៧៧៧០

៣០-១១-២០០៥ -លិខិតលេខ ២៦៩២ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ប៊ី អិម ស៊ី ស៊ី ស៊ី ខូ អិលធីឌី ៧៧៧២

០១-១២-២០០៥ -លិខិតលេខ ២៧០០ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ស៊ូ អ៊ិនធើប្រាយ ៧៧៧៤

០៦-១២-២០០៥ -លិខិតលេខ ២៧១១ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
គ្លូប៊ល អេគ្រីខលឈើរ៉ល ឌីវេឡុបមេន (ខេមបូឌា) លីមីធីត ៧៧៧៦

០៦-១២-២០០៥ -លិខិតលេខ ២៧១២ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ហ្គ្រីន អាយលែន អេគ្រីខលឈើរ៉ល ឌីវេឡុបមេន (ខេមបូឌា) លីមីធីត ៧៧៧៨

០៩-១២-២០០៥ -លិខិតលេខ ២៧៤១ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ធីស៊ី អិចប្រេស រូតូ ស៊ីទីស អេន ស្លេជាត (ខេមបូឌា) តីធីវ៉ាយ
អិលធីឌី ៧៧៨០

០៩-១២-២០០៥ -លិខិតលេខ ២៧៥១ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ទូរគមនាគមន៍កម្ពុជា (ទ.ក) ៧៧៨២

១៣-១២-២០០៥ -លិខិតលេខ ២៧៥៧ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ប្រូខន ខូអិលធីឌី ៧៧៨៤

ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៤៩៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០២/២៥៣ ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិល ទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានផ្ទេរក្របខ័ណ្ឌលោក ជួប សុភក្តិ អនុមន្ត្រី ថ្នាក់លេខ ១៣ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្តីការគណៈរដ្ឋមន្ត្រី ទៅជាអនុមន្ត្រី ថ្នាក់លេខ ១៣ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល-០៥១២-៥២៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៥

លេខ : ៤៦៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាងី តាន់

នស/រកត/១២០៥/៤៥៥

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋ បូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានលុបឈ្មោះឯកឧត្តម ខួន ផនស៊ីផុន ឧត្តមមន្ត្រីថ្នាក់លេខ ១ ចេញពីក្របខ័ណ្ឌ មន្ត្រីគ្រប់គ្រង-រដ្ឋបាល នៃទីស្តីការគណៈរដ្ឋមន្ត្រី ដោយមូលហេតុ ទទួលមរណភាព ។

មាត្រា២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសម្រេចនូវ ព្រះរាជក្រឹត្យនេះ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះនាមលញ្ឆករ
នរោត្តម សីហមុនី

ពរល-០៥១២.៥២៤

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៥

លេខ: ៤៧២ .ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
[signature]
... សាន់ី តាន់

ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៤៥៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ១១រូប
នៃក្រសួងមហាផ្ទៃ ដូចខាងក្រោមនេះ :

ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :
ឯកឧត្តម ឧត្តមសេនីយ៍ឯក ទួល គឿន

ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :
១- លោកឧត្តមសេនីយ៍ត្រី ឯម សំណាង
២- លោក សេង យូអ៊ាន់

គ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ :
១- ឯកឧត្តម ឧត្តមសេនីយ៍ទោ ម៉ាន់ ណយ
២- លោក ទឹម សុផា
៣- លោក ចេស ម៉ាន្នី
៤- លោក ជា ចន្ថា
៥- លោក ជិន ចាយ
៦- លោក ទឹម ណារិទ្ធ
៧- លោក ហ៊ីង ចន្ទដារា
៨- លោក អៀម សុខុន

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរណ: ០៤១២.៥២៥

លេខ: ៤៧០ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៥

ដើម្បីចម្លងចែកជូន
រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាវី តាន់

ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៤៨៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៨០៤/១៧២ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងសមាសភាពនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម សៅ ជីវន្ត ជាសមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៤៥.០៥១២.៥២៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៥

លេខ : ៤៦១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ណារិទ្ធ តាន់

ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៤៨៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១.- ត្រូវបានធ្វើសមាហរណកម្មទៅក្នុងក្របខ័ណ្ឌឧត្តមមន្ត្រី ថ្នាក់ទី ១ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នូវមន្ត្រីរាជការស៊ីវិល ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម **ម៉ុម ជីមហ៊ុយ**

២- ឯកឧត្តម **យស់ សុខ**

៣- ឯកឧត្តម **ឯក សំអុល**

៤- ឯកឧត្តម **ហ៊ូ ស្រ៊ី**

មាត្រា២.- បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣.- សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តអោយបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៤.- ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចរណ.០៥១៧.៥៧៨

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ២០០៥

លេខ : ៤៧៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង តាន

ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៤៩០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

តែងតាំង

លោក ប៊ូ គីមថេង

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរស.០៥១២.៥២៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ,ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៥

លេខ: ៤៧៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឈាង តាន់

ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៤៩១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជាតរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងព្រះអង្គម្ចាស់ក្សត្រីយ៍ ស៊ីសូវត្ថិ គល្យាណទេវី ជាលេខាធិការផ្ទាល់ ព្រះមហាក្សត្រ មានឋានៈស្មើ រដ្ឋលេខាធិការ ។

មាត្រា ២ : ព្រះរាជក្រឹត្យលេខ នស/រកត/១១០៤/០០៥ និងព្រះរាជក្រឹត្យលេខ នស/រកត/១១០៤/០០៦ ចុះថ្ងៃទី 0៤ ខែ វិច្ឆិកា ឆ្នាំ ២00៤ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចចៅហ្វាវាំង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីព្រះបរមរាជវាំង ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣ស.០៥១២.៥៣០
បានប្រថាប់ព្រះរាជលញ្ឆករហើយ
ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៥

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ:0២០/0៥ វ.ចច
រាជធានីភ្នំពេញ,ថ្ងៃទី ៨ ខែធ្នូ ឆ្នាំ២00៥
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង
ហត្ថលេខា និងត្រា
គង់ សំអុល

លេខ : ៤៧៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២00៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
សាខី តាន់

ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៤៩៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណូមពរចាំបាច់នៃការងារ

ត្រាស់បង្គាប់

មាត្រា ១: តែងតាំង ឯកឧត្តម ចែម សខ្វា ជាទីប្រឹក្សាសម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារប្រៃសណីយ៍ និងទូរគមនាគមន៍ មានឋានៈស្មើរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ដោយពុំទទួលប្រាក់បៀវត្ស ។

មាត្រា ២: នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវ ព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរស.០៥១៧.៥៣១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៥

លេខ: ៤៦៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង តាន់

ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៤៩៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា)

តែងតាំង

លោក គឹម ហេង

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ការស-០៩១៧.៥៣៧

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៥

លេខ: ៤១៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវី តាន់

ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៤៩៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និង ថ្នាក់ដឹកនាំរដ្ឋសភា និង សំដែងការទុកចិត្ត ទៅលើសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រធានរដ្ឋសភាស្តីទី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តម្លើងឋានៈឯកឧត្តម ម៉ៅ ញ៉ូ ជាទីប្រឹក្សាផ្ទាល់សម្តេច ហេង សំរិន អនុប្រធានទី១ នៃរដ្ឋសភា នីតិកាលទី៣ ទទួលបន្ទុកសន្តិសុខ មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : ប្រធានរដ្ឋសភា និង នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៣៥.០៤១២.៤៣៣

ថ្វាយទៅព្រះមហាក្សត្រ រាជធានីភ្នំពេញ, ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៥

លេខ : ៤៦៧ ច.ល
ដើម្បីចម្លងចែកជូន
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ តាន់

នស/រកត/១២០៥/៤៩៥

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ជូនថ្នាក់ដឹកនាំ និង សមាជិក
នៃគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ចំនួន ១៣រូប ដូចខាងក្រោមនេះ :

១- ឯកឧត្តម អ៊ុត ចណ្ឌរិទ្ធ
២- ឯកឧត្តម ចាន់ មិន
៣- ឯកឧត្តម ឃឹម ភូនវិហាន
៤- ឯកឧត្តម ទេព ស៊ុំផន
៥- ឯកឧត្តម ម៉ុន ពិសិដ្ឋ
៦- ឯកឧត្តម ហែម គ្រាញ់
៧- ឯកឧត្តម ហោ ឡូត
៨- ឯកឧត្តម អ៊ិត រ៉ាឌី
៩- លោកជំទាវ តាន់ ធានី
១០- លោកជំទាវ ពុំ ចាន់ធិនី
១១- ឯកឧត្តម ញ៉ូខ ស៊ារាប
១២- ឯកឧត្តម ម៉ក់ សម្បត្តិ
១៣- ឯកឧត្តម ហាឡ្យ ឡារ៉ាម៉ានី

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល.០៥១៧.៥៣៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៥

លេខ : ៤៧២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវី តាន់

ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៤៩៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម ឧត្តមសេនីយ៍ឯក អ៊ុន ជើន

នូវ

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល-០៥១២.៥៣៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៥

លេខ: ៤០៧៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាឌី តាន់

នស/រកត/១២០៥/៤៩៨

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ . – តម្លើងឋានន្តរស័ក្តិជូនដល់នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចខាងក្រោម :

ក- ថ្នាក់ឧត្តមសេនីយ៍ទោ :

- លោកឧត្តមសេនីយ៍ត្រី សុខ សងរេន អត្តលេខ ០១០៨ ។

ខ- ថ្នាក់ឧត្តមសេនីយ៍ត្រី :

- លោកវរសេនីយ៍ឯក ម៉ូ បុន អត្តលេខ ០១៣៤១ ។

មាត្រា ២ . – សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ . – ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ : ៤៦៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
សរ៉ាឌី តាន់

ពរល.០៥១២.៥៣៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៥

នស/រកត/១២០៥/៥០០

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

ជាកិច្ចបច្ឆាមរណៈ

ចំពោះ

សព ឯកឧត្តម ណុប លាន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា

ថ្នាក់ ធិបឌិន្ទ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចារស.០៥១២.៥៣៨

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៥

លេខ : ៤៧៥.ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាឌី តាន់

ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៥០១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណូមពរចាំបាច់នៃការងារ

ត្រាស់បង្គាប់

មាត្រា ១: តែងតាំង ឯកឧត្តម **គុង សេង** ជាទីប្រឹក្សាសម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារវិនិយោគ មានឋានៈស្មើអនុរដ្ឋលេខាធិការ ដោយពុំទទួលប្រាក់បៀវត្ស ។

មាត្រា ២: នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវ ព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល-០៥១២.៥៣

ធ្វើនៅព្រះបរមរាជវាំង·រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៥

លេខ: ៤៧០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាឌី តាន់

ព្រះរាជក្រឹត្យ

នស/រកត/១២០៥/៥០៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានផ្ទេរក្របខ័ណ្ឌ លោក ឃួ ប៉ាសិទ្ធិ អនុមន្ត្រី ថ្នាក់លេខ ១៣ នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ទៅជាអនុមន្ត្រី ថ្នាក់លេខ ១៣ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងកិច្ចការនារី ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ថ្ងៃទៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៥

ពរល.០៥១៧.៥៤៥

លេខ ៤៧៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

សៅ តាន់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...១៤១...អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង នៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

សម្រេច

មាត្រា១ :

ត្រូវបានបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង ដែលចំណុះផ្ទាល់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

មាត្រា២ :

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ទទួលបន្ទុកអនុវត្តភារកិច្ចតាមអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង នៅតាមបណ្តាស្ថាប័ន ក្រសួង និង សហគ្រាសសាធារណៈ ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

រចនាសម្ព័ន្ធ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

មាត្រា៣ :

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៤ :

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ស៊ុយ សែម

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចមាត្រា ៤
- កាលប្បវត្តិ-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៤៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្ទេរឥណទានថវិកា

****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧. ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤. ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០.ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ១២០៤/ ០០២ .ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩២ អនក្រ.បក , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ១.៧៥០ លានរៀល (មួយពាន់ប្រាំពីររយហាសិបលានរៀលគត់) ពីជំពូក ៤០ (ចំណាយផ្សេងៗ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការផ្គត់ផ្គង់តូច) សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់បោះពុម្ពទិន្នាការស្ថិត និង បោះពុម្ពលតាប័ត្រវថយន្ត ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៤៣ អនក្រ . បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៧០៤/១១៧ , ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ ។
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦-១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ,បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៤/០០២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៤ ។
- បានឃើញអនុក្រឹត្យលេខ ៩២ អនក្រ,បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៤ របស់រាជរដ្ឋាភិបាល ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ។
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា១ : ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៣០០.០០០.០០០រៀល (បីរយលានរៀលគត់) ពីជំពូក ៣០ (អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច) មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការផ្គត់ផ្គង់) របស់ក្រសួងសាធារណការ និង ដឹកជញ្ជូន សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ។

មាត្រា២ : ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់បំពេញខ្វះចំណាយសកម្មភាពអាសន្នដែលក្រោងខ្វះក្នុងឆ្នាំ ២០០៥ ។

មាត្រា៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ-ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៤៤ អនក្រ . បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៧០៤/១១៧ , ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ ។
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦-១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៤/០០២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៤ ។
- បានឃើញអនុក្រឹត្យលេខ ៩២ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៤ របស់រាជរដ្ឋាភិបាល ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ។
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា១ : ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ១.៣០៧.០០០.០០០រៀល (មួយពាន់បីរយប្រាំពីរលានរៀលគត់) ពីជំពូក ៣០ (អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច) មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច) របស់ក្រសួងពាណិជ្ជកម្ម សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ។

មាត្រា២ : ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់បំពេញខ្វះចំណាយសកម្មភាពអាស៊ានដែលគ្រោងខ្វះក្នុងឆ្នាំ ២០០៥ ។

មាត្រា៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ-ឯកសារ

បានយកសេចក្ដីជំរាបជូន
សម្ដេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៤៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ឯកសណ្ឋាន សញ្ញាសក្តិ និងផ្លាកសញ្ញាសំគាល់របស់ នាយកដ្ឋានកម្ពុជា ត្រួតពិនិត្យទំនិញនីហាំរណ-អាហាំរណ និងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល "

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និងសេវា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតឯកសណ្ឋាន និងផ្លាកសញ្ញាសំគាល់ របស់នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល "
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សម្រេច

មាត្រា ១.-

អនុក្រឹត្យនេះសម្រាប់ជំនួសឱ្យអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតឯកសណ្ឋាន និងផ្លាកសញ្ញាសំគាល់ របស់នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និង បង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល " ដោយអនុញ្ញាតឱ្យនាយកដ្ឋានកម្ពុជា ត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និង បង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល " បង្កើតឯកសណ្ឋាន សញ្ញាសក្តិ និងផ្លាកសញ្ញាសំគាល់ សម្រាប់មន្ត្រីរាជការ ប្រើប្រាស់ក្នុងពេលប្រតិបត្តិការ ។

មាត្រា ២.-

ឯកសណ្ឋាន សញ្ញាសក្តិ និងផ្លាកសញ្ញាសំគាល់របស់ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល " ត្រូវបានកំណត់ដូចតទៅ ÷

១-ឯកសណ្ឋាន :

- **ខោអាវ** ចំនួន ២ ពណ៌ពងក្រសា ផលិតអំពីសាច់ក្រណាត់តេហ្គាលឡែន ចង្កេះ ត ផ្ទេរបង្កប់ជីបក្លីខាងមុខពីរ មានហោប៉ៅបី " ហោប៉ៅខាងក្រោយមួយ ដេរបង្កប់ មានគំរបរាងស្លឹកពោធិ និងហោប៉ៅពីរទៀតនៅចំហៀង ដេរ បង្កប់តាមផ្ទេរ " ។

- **អាវ** មានពីរថ្នាក់ :

  - **ថ្នាក់ដឹកនាំនាយកដ្ឋាន ពាណិជ្ជកម្ម និង សាខា :**

    អាវដៃខ្លីចំនួនពីរ មានពណ៌ និងសាច់ក្រណាត់ដូចខោ កបើក ផ្ទេរខុប ប៉ូលស្មា ជីបចង្កេះ មានហោប៉ៅបួន " ហោប៉ៅពីរខាងលើដេរប៉ះបត់ផ្នត់ កណ្តាល មានគំរបរាងស្លឹកពោធិ ហោប៉ៅផ្តោកពីរខាងក្រោម ដេរប៉ះ មានគំរបរាងស្លឹកពោធិ ។

  - **ថ្នាក់មន្ត្រីប្រតិបត្តិ :**

    អាវដៃវែងមួយ អាវដៃខ្លីមួយ ពណ៌ និងសាច់ក្រណាត់ដូចខោ កខុប ផ្ទេរខុប ចោះឡេវចុងក ប៉ូលស្មា ហោប៉ៅពីរដេរប៉ះ បត់ផ្នត់កណ្តាល មានគំរបរាងស្លឹកពោធិ កាត់ស្រុងវែង ជើងត្រង់ដាក់ក្នុងខោ ។

- **ខ្សែក្រវាត់ជើង** ក ខ្លី ពណ៌ ខ្មៅ ស្រោមជើងខ្មៅ ។

- **មួកពាក់ក្បាល** មាន ៤ ថ្នាក់ :

  - **ថ្នាក់ដឹកនាំនាយកដ្ឋាន :**

    មួកកាស្កែតធ្វើពីក្រណាត់ពណ៌ដូចខោ ដែលផ្នែកខាងមុខ លើកណ្តាប់ វីល្ល មានភ្ជាប់រូបព្រះសង្ខាពណ៌មាស ទំហំកំពស់ ៧,៨ ស.ម ទទឹង ៦,៨ ស.ម បៃកខាងក្រោមនៃជើងមួក និងក្រោមព្រះសង្ខាមានកណ្តាប់វីល្លធ្វើពីក្រណាត់

ខ្សែនពណ៌ខៀវទឹកប៊ិចព័ទ្ធជុំវិញ ។ ខាងក្រោមកណ្តាប់វីណ្ណបែកខាងមុខ មានក្បាំងពណ៌ខ្មៅ ។ ផ្នែកខាងមុខ ក្រោមកណ្តាប់វីណ្ណ ដែលនៅពីលើក្បាំង មានកម្រងខ្សែសយពណ៌មាស ព្រមទាំងនៅចុងខ្សែទាំងពីរខាងភ្ជាប់ដោយឡេវព្រះសង្ខាពណ៌មាស ។ នៅលើក្បាំងមួក មានបាំនក្បាច់ភ្ញីទេសឱនពណ៌មាស ទម្រង់ស្នែងក្របីដល់ជើងមួក ។

- **ថ្នាក់ការិយាល័យ និង បណ្តាសាខា :**

មានរូបភាព និងម៉ូតដូចថ្នាក់ដឹកនាំនាយកដ្ឋានដែរ តែខុសគ្នា ត្រង់នៅលើក្បាំងមួក មានបាំនក្បាច់ភ្ញីទេសឱន ពណ៌មាស ទម្រង់ស្នែងក្របី ដោយចុងសងខាង ទុកចន្លោះ ៤ ស.ម ពីជើងមួក ។

- **ថ្នាក់ប្រធានប៉ុស្តិ៍ :**

មានរូបភាព និងម៉ូតដូចថ្នាក់ការិយាល័យ និងសាខាដែរ តែខុសគ្នា ត្រង់ផ្នែកខាងមុខ លើកណ្តាប់វីណ្ណមានភ្ជាប់រូបព្រះសង្ខាពណ៌ប្រាក់ និងផ្នែកខាងមុខក្រោមកណ្តាប់វីណ្ណ ដែលនៅពីលើក្បាំងមួកមាន កម្រងខ្សែសយពណ៌ប្រាក់ ព្រមទាំងនៅចុងខ្សែទាំងសងខាង ភ្ជាប់ដោយឡេវរូបព្រះសង្ខាពណ៌ប្រាក់ នៅលើក្បាំងមួក មានឆ្នូតពណ៌ប្រាក់ ដល់ជើងមួក ។

- **ថ្នាក់មន្ត្រីភ្នាក់ងារ :**

មានរូបភាព និងម៉ូតដូចថ្នាក់ប្រធានប៉ុស្តិ៍ដែរ ខុសគ្នាត្រង់នៅលើក្បាំងមួក គ្មានឆ្នូតពណ៌ប្រាក់ទេ ។

ឯកសណ្ឋានដូចបានរៀបរាប់ខាងលើ សម្រាប់ស្លៀកពាក់ធ្វើការក្នុងការិយាល័យ និងចុះបំពេញបេសកកម្មការងារ ឬទាក់ទងស្ថាប័ននានាក្នុងប្រទេស ។

រូបគំរូនៃឯកសណ្ឋាន ថ្នាក់ដឹកនាំនាយកដ្ឋាន ការិយាល័យ សាខា និងថ្នាក់មន្ត្រីភ្នាក់ងារ **មានដូចក្នុង ឧបសម្ព័ន្ធទី ១ ទី២ និង ទី៣** ។

៦-ផ្លាកសញ្ញាសំគាល់ :

ផ្លាកសញ្ញាសំគាល់ របស់នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល " ត្រូវបានកំណត់ដូចខាងក្រោម ÷

សញ្ញា កាំកុងត្រូល មានរាងពងក្រពើ ។

➢ ផ្ទៃខាងក្នុងមាន :

- រូបប្រាសាទកំពូល ៣ តំណាងអោយព្រះរាជាណាចក្រកម្ពុជា
- រូបផែនទីសកលលោក តំណាងអោយទ្វីប សហគមន៍ ឬតំបន់ទំនាក់ទំនងលើកិច្ចការត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ ។
- រូបជញ្ជីង តំណាងអោយអាជ្ញាកណ្តាល ឯករាជ្យ អព្យាក្រឹត្យ និង យុត្តិធម៌
- រូបកែវ ពង្រីក (ពណ៌ ស នៅចំកណ្តាល បញ្ឆិតជញ្ជីង) តំណាងអោយការងារត្រួតពិនិត្យគុណភាព បង្ក្រាបការក្លែងបន្លំគុណភាពទំនិញ កម្មសិទ្ធិបញ្ញា និងសុវត្ថិភាព ម្ហូបអាហារទីផ្សារពាណិជ្ជកម្ម ។

➢ នៅរង្វង់ខាងក្រៅ រូបខាងលើ : មានអក្សរពណ៌ ទឹកប៊ិច ដាក់ថា ព្រះរាជាណាចក្រកម្ពុជា

➢ នៅរង្វង់ខាងក្រៅ រូបខាងក្រោម : មានអក្សរពណ៌ ទឹកប៊ិច ដាក់ថា កាំកុងត្រូល ជាអក្សរខ្មែរ និងអក្សរឡាតាំង រូបគំរូផ្លាកសញ្ញាសំគាល់ មានដូចក្នុង ឧបសម្ព័ន្ធទី ៤ ។

ផ្លាកសញ្ញាសំគាល់ដាក់លើសញ្ញាសក្តិលើស្មា សម្រាប់ពាក់លើចុងកអាវឆ្វេង ស្តាំ ដេរភ្ជាប់លើដើមដៃអាវខាងស្តាំ សម្រាប់ដាក់ផ្លាកឈ្មោះ ។

ក-ផ្លាកសញ្ញាសម្រាប់ពាក់លើចុងកអាវ ឆ្វេង ស្តាំ

កំណត់យកតាមផ្លាកសញ្ញាសំគាល់របស់នាយកដ្ឋាន កម្ពុជាត្រួតពិនិត្យទំនិញ ទីហ័រណ-អាហ័រណ និងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល " ដែលមានរាងមូលទំហំ ២,៣ ស.ម ធ្វើអំពីស្ពាន់ និង ក្រូមេ (សម្រាប់មន្ត្រី ភ្នាក់ងារ)

មានរូបភាពដូចផ្លាកសញ្ញាចុងកអាវ របស់មន្ត្រីភ្នាក់ងារដែរ តែត្រង់មានទំហំធំជាង គឺ ២.៥ ស.ម មានរាងប៉ោង មានទម្រស្លឹកឈើចំនួនពីរមែកខ្វែងគ្នារំលេចដោយពណ៌មាសស្រោបកែវភ្លឺ (សម្រាប់ថ្នាក់ដឹកនាំ) ។

ខ-ផ្លាកសញ្ញាកាំកុងត្រូលដេរភ្ជាប់លើដើមដៃអាវខាងស្តាំ

កំណត់យកផ្លាករាងពងក្រពើ (ទំហំបន្ទាត់ផ្ចិត៨ស.ម) ធ្វើអំពីសាច់ក្រណាត់ ដែលប៉ាក់ដោយកំព្យូទ័រនិងអំបោះសូត្រ ។ ផ្ទៃខាងក្នុងពណ៌ផ្ទៃមេឃ ផ្នែកខាងក្រោមមានរូបជញ្ជីងពណ៌លឿង ។ ផ្នែកខាងលើមានបន្ទាត់ស្របនឹងខ្សែបន្ទាត់កាត់ទទឹងពណ៌ស ។ ផ្នែកខាងលើបង្អស់នៃផ្លាករាងពងក្រពើមានសរសេរអក្សរខ្មែរពណ៌លឿងទឹកប៊ិច " កាំកុងត្រូល " ។ ផ្នែកខាងក្រោមបង្អស់សរសេរអក្សរឡាតាំងពណ៌ខៀវទឹកប៊ិច " CAMCONTROL " ព័ទ្ធជុំវិញផ្លាករាងពងក្រពើ ដោយខ្សែបន្ទាត់ពណ៌លឿងបិទជិត ។

ទន្ទឹមនោះត្រូវមានផ្លាកសញ្ញាក្រសួងពាណិជ្ជកម្ម និង ផ្លាកសញ្ញាសំគាល់មន្ត្រី កាំកុងត្រូល :

ក-ផ្លាកសញ្ញាក្រសួងពាណិជ្ជកម្ម

ផ្លាកសញ្ញាក្រសួងពាណិជ្ជកម្ម មានរូបសញ្ញារបស់ក្រសួងពាណិជ្ជកម្ម ដែលរំលេចដោយរូបភាព និងពិណប្រចាំក្រសួង មានរាងមូលប៉ោងទំហំ ៤.៧ ស.ម ធ្វើអំពីស្ពាន់ភ្ជាប់ដោយបន្ទះស្បែក សម្រាប់ពាក់នៅលើហោប៉ៅអាវស្តាំ ។

ខ-ផ្លាកសំគាល់ឈ្មោះមន្ត្រី

កំណត់យកផ្លាករាងបួនជ្រុងទ្រវែង ទំហំបណ្តោយ ១០ ស.ម ទទឹង ២ស.ម ធ្វើអំពីជាតិជ័ររឹង ។ ផ្ទៃខាងក្នុងពិណខៀវទឹកប៊ិច ព័ទ្ធជុំវិញដោយខ្សែបន្ទាត់ពិណស បិទជិត។ ផ្នែកខាងលើសរសេរឈ្មោះមន្ត្រីរាជការជាអក្សរខ្មែរ ។ ផ្នែកខាងក្រោមសរសេរអត្តលេខមន្ត្រី រាជការជាអក្សរឡាតាំង ។

៣-សញ្ញាសក្តិស្មា ៈ ខ្នាតសញ្ញាសក្តិស្មា ត្រូវបានកំណត់ដូចខាងក្រោម :

-បាតក្រោមប្រវែង ៦ សង្ទីម៉ែត្រ

-បណ្តោយពីលើដល់បាតក្រោមប្រវែង ១៣ សង្ទីម៉ែត្រ

-ទទឹងមុខកាត់ផ្នែកខាងលើប្រវែង ៤.៤០ សង្ទីម៉ែត្រ មានរាងកោងជាមុំទាល

សញ្ញាសក្តិស្មាត្រូវបានរៀបចំដោយឡែកជា៥ថ្នាក់ ខុស១គ្នា សម្រាប់សំគាល់ថ្នាក់ប្រធាននាយកដ្ឋាន សម្រាប់សំគាល់ថ្នាក់អនុប្រធាននាយកដ្ឋាន សម្រាប់ថ្នាក់ប្រធាន

ការិយាល័យ និងថ្នាក់ប្រធានសាខា សម្រាប់ថ្នាក់អនុប្រធានការិយាល័យ និងថ្នាក់អនុប្រធានសាខា និង សម្រាប់ថ្នាក់មន្ត្រីភ្នាក់ងារ ។

ក-សម្រាប់ថ្នាក់ប្រធាននាយកដ្ឋាន :

មានផ្ទៃពណ៌ខៀវទឹកប៊ិច នៅផ្នែកខាងក្រោមបង្អស់ មានចម្លាក់ក្បាច់អង្គរពណ៌មាស នៅលើក្បាច់នេះមានអក្សរ កាំកុងត្រូល ពណ៌មាស នៅលើអក្សរមានសញ្ញាកាំកុងត្រូល ពណ៌មាស ហើយនៅលើសញ្ញានេះ មានឡេវរូបព្រះរាជសង្ហារ ពណ៌មាសមួយ មានក្បាច់ភ្ញីទេស ពណ៌មាស ព័ទ្ធជុំវិញ ហើយនឹងមានខ្សែពួរវេញ បី ខ្សែ ពណ៌មាសព័ទ្ធជុំវិញខាងក្រៅ **រូបគំរូសញ្ញាសក្តិប្រធាននាយកដ្ឋាន មានដូចក្នុង ឧបសម្ព័ន្ធទី ៥** ។

ខ-សម្រាប់ថ្នាក់អនុប្រធាននាយកដ្ឋាន :

មានផ្ទៃ ពណ៌ខៀវទឹកប៊ិច នៅផ្នែកខាងក្រោមបង្អស់ មានចម្លាក់ក្បាច់អង្គរពណ៌មាស នៅលើក្បាច់នេះមានអក្សរ កាំកុងត្រូល ពណ៌មាស នៅលើអក្សរមានសញ្ញាកាំកុងត្រូល ពណ៌មាស ហើយនៅលើសញ្ញានេះ មានឡេវរូបព្រះរាជសង្ហារ ពណ៌មាស មួយ មានក្បាច់ភ្ញីទេស ពណ៌មាស ព័ទ្ធជុំវិញ ហើយនឹងមានខ្សែពួរវេញ ពីរ ខ្សែ ពណ៌មាសព័ទ្ធជុំវិញខាងក្រៅ **រូបគំរូសញ្ញាសក្តិអនុប្រធាននាយកដ្ឋាន មានដូចក្នុង ឧបសម្ព័ន្ធទី ៦** ។

គ-សម្រាប់ថ្នាក់ប្រធានការិយាល័យ និង ប្រធានសាខា :

មានផ្ទៃ ពណ៌ខៀវទឹកប៊ិច នៅផ្នែកខាងក្រោមបង្អស់ មានចម្លាក់ក្បាច់អង្គរពណ៌មាស នៅលើក្បាច់នេះមានអក្សរ កាំកុងត្រូល ពណ៌មាស នៅលើអក្សរមានសញ្ញាកាំកុងត្រូល ពណ៌មាស ហើយនៅលើសញ្ញានេះ មានឡេវរូបព្រះរាជសង្ហារ ពណ៌មាស មួយ មានក្បាច់ភ្ញីទេស ពណ៌មាស ព័ទ្ធជុំវិញ ហើយនឹងមានខ្សែពួរវេញ មួយ ខ្សែ ពណ៌មាសព័ទ្ធជុំវិញខាងក្រៅ **រូបគំរូសញ្ញាសក្តិ ប្រធានការិយាល័យ ប្រធានសាខា មានដូចក្នុង ឧបសម្ព័ន្ធទី ៧** ។

ឃ-សម្រាប់ថ្នាក់អនុប្រធានការិយាល័យ និង អនុប្រធានសាខា :

មានផ្ទៃ ពណ៌ខៀវទឹកប៊ិច នៅផ្នែកខាងក្រោមបង្អស់ មានចម្លាក់ក្បាច់អង្គរពណ៌មាស នៅលើក្បាច់នេះមានអក្សរ កាំកុងត្រូល ពណ៌ប្រាក់ នៅលើអក្សរមានសញ្ញាកាំកុងត្រូល ពណ៌ប្រាក់ ហើយនៅលើសញ្ញានេះ មានឡេវរូបព្រះរាជសង្ហារ ពណ៌ប្រាក់ មួយ មានក្បាច់ភ្ញីទេស ពណ៌មាស ព័ទ្ធជុំវិញ ហើយនឹងមានខ្សែពួរវេញ មួយខ្សែ ពណ៌មាសព័ទ្ធជុំវិញខាងក្រៅ **រូបគំរូសញ្ញាសក្តិ អនុប្រធានការិយាល័យ អនុប្រធានសាខា មានដូចក្នុង ឧបសម្ព័ន្ធទី ៨** ។

ង-សម្រាប់ថ្នាក់មន្ត្រីភ្នាក់ងារ :

មានផ្ទៃ ពណ៌ខៀវទឹកប៊ិច នៅផ្នែកខាងក្រោមបង្អស់ មានចម្លាក់ក្បាច់អង្គរពណ៌ប្រាក់ នៅលើក្បាច់នេះមានអក្សរ កាំកុងត្រូល ពណ៌ប្រាក់ នៅលើអក្សរមានសញ្ញាកាំកុងត្រូល ពណ៌ប្រាក់ ហើយនៅលើសញ្ញានេះ មានឡេវរូបព្រះរាជសង្ហារ ពណ៌ប្រាក់ មួយ មានក្បាច់ភ្ញីទេស ពណ៌ប្រាក់ ព័ទ្ធជុំវិញ ហើយនឹងមានខ្សែពួរវេញ មួយ ខ្សែ ពណ៌ប្រាក់ព័ទ្ធជុំវិញខាងក្រៅ **រូបគំរូសញ្ញាសក្តិមន្ត្រីភ្នាក់ងារ** មានដូចក្នុង **ឧបសម្ព័ន្ធទី ៩** ។

មាត្រា ៣.-

ក្នុងពេលប្រតិបត្តិការ មន្ត្រីរាជការកាំកុងត្រូលទាំងពីរភេទ ត្រូវស្លៀកពាក់ឯកសណ្ឋាន សញ្ញាសក្តិ និង ពាក់ផ្លាកសញ្ញាសំគាល់ និងត្រូវមានលិខិតបញ្ជាបេសកកម្ម ជាប់តាមខ្លួនផង ។ ក្នុងពិធីប្រជុំ ឬពិធីផ្សេងៗទៀត បើចាំបាច់ ត្រូវស្លៀកពាក់ឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសំគាល់ផងដែរ ។

មាត្រា ៤.-

ជនក្លែងបន្លំខ្លួន ដោយស្លៀកពាក់ឯកសណ្ឋាន សញ្ញាសក្តិ និង សញ្ញាសំគាល់ ដូចមានចែងក្នុង អនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

មាត្រា ៥.-

អនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតឯកសណ្ឋាន និងផ្លាកសញ្ញាសំគាល់ របស់នាយកដ្ឋានកម្ពុជា ត្រួតពិនិត្យទំនិញ នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល " និងបទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីសុំហត្ថលេខា

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី ១

នៃអនុក្រឹត្យលេខ ១៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៥
ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងផ្លាកសញ្ញាសំគាល់របស់ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យ
ទំនិញនាំចេញ-នាំចូល និងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល "

ឯកសណ្ឋានសម្រាប់ ប្រធាន-អនុប្រធាននាយកដ្ឋាន



ឧបសម្ព័ន្ធទី ២

នៃអនុក្រឹត្យលេខ ១៤៥ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៥
ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងផ្លាកសញ្ញាសំគាល់របស់ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យ
គុណភាពទំនិញនិងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល "

ឯកសណ្ឋានសម្រាប់ ប្រធាន-អនុប្រធានការិយាល័យ



ឧបសម្ព័ន្ធទី ៣

នៃអនុក្រឹត្យលេខ១៥៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែ ធ្នូ ឆ្នាំ ២០០៥
ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងផ្លាកសញ្ញាសំគាល់របស់ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យ
ទំនិញនាំចេញ-នាំចូល និងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល "

ឯកសណ្ឋានសម្រាប់ ភ្នាក់ងារ



ឧបសម្ព័ន្ធទី ៤

អនុក្រឹត្យលេខ ១៤៥ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ ១២ ឆ្នាំ ២០០៥
ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងផ្លាកសញ្ញាសំគាល់របស់ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ
នីហាំណ-អាហាំណ និងបង្ក្រាបការក្លែងបន្លំ "កាំកុងត្រូល"

ផ្លាកសញ្ញាសំគាល់របស់
នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហាំណ-អាហាំណ និងបង្ក្រាបការក្លែងបន្លំ

ឧបសម្ព័ន្ធទី ៥

នៃអនុក្រឹត្យលេខ ១៤៥ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងផ្លាកសញ្ញាសំគាល់របស់ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យ ទំនិញនីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល "

សញ្ញាសក្តិសម្រាប់ ប្រធាននាយកដ្ឋាន



ឧបសម្ព័ន្ធទី ៦

នៃអនុក្រឹត្យលេខ ១៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៥
ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងផ្លាកសញ្ញាសំគាល់របស់ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យ
ទំនិញនីហរិណ-អាហរិណ និងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល "

សញ្ញាសក្តិសម្រាប់ អនុប្រធាននាយកដ្ឋាន

ឧបសម្ព័ន្ធទី ៧

នៃអនុក្រឹត្យលេខ១៥៥អនក្រ.បក ចុះថ្ងៃទី២៣ ខែ ធ្នូ ឆ្នាំ ២០០៥
ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងផ្លាកសញ្ញាសំគាល់របស់ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យ
ទំនិញនីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល "

សញ្ញាសក្តិសម្រាប់ ប្រធានការិយាល័យ និងប្រធានសាខា

ឧបសម្ព័ន្ធទី ៨

នៃអនុក្រឹត្យលេខ ១៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៥
ស្តីពីឯកសណ្ឋាន សញ្ញាសក្តិ និងផ្លាកសញ្ញាសំគាល់របស់ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យ
ទំនិញនីហរណ៍-អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ " កាំកុងត្រូល "

សញ្ញាសក្តិសម្រាប់ អនុប្រធានការិយាល័យ និងអនុប្រធានសាខា

ឧបសម្ព័ន្ធទី ៩

នៃអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៥
ស្ដីពីឯកសណ្ឋាន សញ្ញាសក្តិ និងផ្លាកសញ្ញាសំគាល់របស់ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យ
ទំនិញនាំចេញ-នាំចូល និងបង្ក្រាបការក្លែងបន្លំ " ការីកុងត្រូល "

សញ្ញាសក្តិសម្រាប់ ភ្នាក់ងារ



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៥៧ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការប្រគល់ភារកិច្ចជូននាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃព្រះរាជក្រឹត្យនគរបាលជាតិ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ .-

ត្រូវបានប្រគល់ភារកិច្ចជូនលោកវរសេនីយ៍ឯក នុន ខ្មែរឧសភា អត្តលេខ ៥៦០៣៥ អោយទទួលមុខងារជាអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ។

មាត្រា ២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨៥៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនលោក **យី យ៉ាណារ៉ាត្ន** អោយបំពេញមុខងារជាប្រធាននាយកដ្ឋានរៀបចំដែនដី នៃអគ្គនាយកដ្ឋានរៀបចំដែនដី និង នគររូបនីយកម្ម នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ_កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០២រូប ដែលបានផ្តល់ថវិកាជួយកសាងអគារសិក្សា ០១ខ្នង មាន០៥បន្ទប់ ធ្វើអំពីថ្ម ប្រក់ក្បឿង បំពាក់ដោយគ្រឿងសង្ហារិមគ្រប់គ្រាន់ និងបង្គន់អនាម័យ ០៤បន្ទប់ នៅក្នុងបរិវេណវិទ្យាល័យ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ-អូរអំបិល ឃុំអូរអំបិល ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម :-

១-លោក **ម៉ាតាំង ម៉ាំងឌីយ៉ូ** (MARTIN MAINDIAUX) អ្នកសំរបសំរួល នៃអង្គការកុមារមេត្តា ខេត្តបន្ទាយមានជ័យ ថវិកា ចំនួន ២២.៤១០.៥៨ ដុល្លារ ។

២-លោក **បឺណូរ ដឺប្លង់ព្រេ** (BENOIT DE BLANPRE) អ្នកស្វះស្វែងរកថវិកា នៅបរទេស នៃអង្គការកុមារមេត្តា ទីក្រុងប៉ារីស ថវិកា ចំនួន ១១.៣៧១ ដុល្លារ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ... ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: [illegible]

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តឧត្តរមានជ័យ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូននាយកកម្មវិធី នាយក និងមន្ត្រីគំរោង ចំនួន ០៤រូប នៃអង្គការ *ចេសាក់* (JASAC) Japan assistance Team for small A ms management in Cambodia ដែលបានផ្តល់មូលនិធិជាច្រើនដល់ខេត្តឧត្តរមានជ័យ ក្នុងការកាត់បន្ថយអាវុធធុនតូច ជួយកសាងសមិទ្ធផល នៅក្នុងស្រុកសំរោង ស្រុកអន្លង់វែង ស្រុកត្រពាំងប្រាសាទ ស្រុកបន្ទាយអំពិល និងស្រុកចុងកាល់ និងជួយឧបត្ថម្ភដល់នគរបាល ខេត្តឧត្តរមានជ័យ ចំណាយអស់ទឹកប្រាក់ សរុបចំនួន ៤៨៦.៦៤៤ ដុល្លារ ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :

១-លោក **គូដូ ស៊ុនអ៊ីជី** (Kudo Shunichi) នាយកកម្មវិធី

២-លោក **ហ្គេម៉ា កេនថារ៉ូ** (Gemma Kentaro) នាយកគំរោង

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :

១-លោក **ឃីដា យ៉ាស៊ូមីស៊ុ** (Kida Yashumitsu) មន្ត្រីគំរោង

២-កញ្ញា **ហ៊ីរ៉ាគី យូកាកូ** (Hiraki Yukako) មន្ត្រីគំរោង

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: [illegible] អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

១៣

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូននាយទាហានជាន់ខ្ពស់ នៃកងទ័ពប្រជាជនវៀតណាម ដែលមានស្នាដៃល្អ ក្នុងកិច្ចសហប្រតិបត្តិការ ជាមួយកងយោធពលខេមរភូមិន្ទ ដូចមានរាយនាមខាងក្រោម :-

១-ឯកឧត្តម ឧត្តមសេនីយ៍ទោ **ឡេ ម៉ាញ់** (Maj Gen LE MANH) មេបញ្ជាការយោធភូមិភាគ ទី ៧ នៃកងទ័ពប្រជាជនវៀតណាម

២-ឯកឧត្តម ឧត្តមសេនីយ៍ត្រី **ទ្រឿវ ស៊ុនហ្វា** Brj Gen TRIEU XUAN HOA មេបញ្ជាការរងយោធភូមិភាគ ទី៧ នៃកងទ័ពប្រជាជនវៀតណាម

៣-ឯកឧត្តម ឧត្តមសេនីយ៍ត្រី **ង្វៀង ថាញ់គុង** Brj Gen NGUYEN THANH CUNG ប្រធាននយោបាយយោធភូមិភាគ ទី៧ នៃ កងទ័ពប្រជាជនវៀតណាម

៤-ឯកឧត្តម **ឡេ ថាញ់ហាយ** H.E LE THANH HAI អភិបាលក្រុងហូជីមិញ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល :</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៨៦៧ អនក្រ.បក

អនុក្រឹត្យ

ស្ដីពីការជូនមេដាយសហមេត្រី

៛

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១: ត្រូវបានចំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ជូនមន្ត្រីយោធាចិន ចំនួន០២រូប ដែលបានមកបំពេញបេសកកម្ម នៅព្រះរាជាណាចក្រកម្ពុជា សម្រេចបានលទ្ធផលល្អ ដូចមានរាយនាមខាងក្រោម :-

ក_មេដាយសហមេត្រី ថ្នាក់ សេនា :

-វរសេនីយ៍ឯក **ហួង លីយុន** (Senior Colonel Huang Liyun) អនុព័ន្ធយោធា នៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា ។

ខ_មេដាយសហមេត្រី ថ្នាក់ អស្សឫទ្ធិ :

-អនុសេនីយ៍ឯក **ប៉ាន គុន** (Captain Pan Kun) ជំនួយការអនុព័ន្ធយោធា នៃ សាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ ✗✗

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:៨៥៣ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងជំនួយការ ពីររូប របស់ឯកឧត្តម វេង សិរីវុឌ្ឍ ទេសរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិទេសចរណ៍កម្ពុជា និងជាប្រធានក្រុមការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រ ដូចមាននាមដូចខាងក្រោម :

១- លោក **ពុន ចន្ណ្ណទី** ជាជំនួយការ មានឋានៈស្មើ អគ្គនាយករង បន្ថែមលើមុខងារបច្ចុប្បន្ន

២- លោក **ម៉ក់ រ័ត្ន** ជាជំនួយការ មានឋានៈស្មើ ប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែ ធ្នូ ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៧០៩៤...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០៧រូប ដែលបានបរិច្ចាគធនធានចូលរួមជួយកសាងយោធភូមិភាគពិសេស និងយោធភូមិភាគទី៤ ដូចមានរាយនាមខាងក្រោម :-

១-ឯកឧត្តម ឧត្តមសេនីយ៍ទោ **ជា មិន** មេបញ្ជាការយោធភូមិភាគទី៤ ទឹកប្រាក់ចំនួន ១០.០០០ ដុល្លារ

២-ឯកឧត្តម ឧត្តមសេនីយ៍ទោ **ព្រហ្ម ឌិន** មេបញ្ជាការយោធភូមិភាគពិសេស ទឹកប្រាក់ចំនួន ១០.០០០ ដុល្លារ

៣-ឯកឧត្តម **ស៊ិន អឿន** អភិបាលរងទី១ ខេត្តសៀមរាប ទឹកប្រាក់ចំនួន ១០.០០០ ដុល្លារ

៤-លោកជំទាវ **មាស សន ~ ជា មិន** ទឹកប្រាក់ចំនួន ១០.០០០ ដុល្លារ

៥-លោកវរសេនីយ៍ឯក **ង្វៀង ដន់កេត** (Col NGUYEN DOAN KET) ប្រធានអនុព័ន្ធយោធាវៀតណាមប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ទឹកប្រាក់ចំនួន ១០.០០០ ដុល្លារ

៦-លោកវរសេនីយ៍ឯក **គង់ ផា** នាយការិយាល័យទី២ យោធភូមិភាគទី៤ ទឹកប្រាក់ចំនួន ១០.០០០ ដុល្លារ

៧-លោកវរសេនីយ៍ឯក **ឡេង ឃួ** នាយសេនាធិការរង កងរាជអាវុធហត្ថខេត្តព្រះវិហារ ទឹកប្រាក់ចំនួន ១៨.០០០ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ [illegible] ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចចែងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៨២៥ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តឧត្តរមានជ័យ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីក្រុមការងារ ចំនួន១០រូប នៃអង្គការ *ចេសាក់* (JASAC) Japan assistance Team for small A ms management in Cambodia ដែលមានស្នាដៃល្អក្នុងការអនុវត្តគំរោង និងកម្មវិធីផ្តល់មូលនិធិជួយដល់ខេត្តឧត្តរមានជ័យ ដូចមានរាយនាមខាងក្រោម :-

១-លោក	**ឈឹម ស៊ីខុន**	មន្ត្រីសំរបសំរួលថ្នាក់ខេត្ត
២-លោក	**ឥន្ទ ទុដ្ឋី**	នាយក តំបន់
៣-លោក	**សន សារ៉ុខ**	នាយក តំបន់
៤-លោក	**សេខ ឃុន**	នាយក តំបន់
៥-លោក	**ឈៀង សែ**	នាយក តំបន់
៦-លោក	**នូច តារា**	មន្ត្រី គំរោង
៧-លោក	**ឃុយ សុឃឿន**	មន្ត្រី គំរោង
៨-កញ្ញា	**ពូ ពេជ្ររចនា**	គណនេយ្យ
៩-លោក	**ឡេខ ធារិទ្ធ**	អ្នកបកប្រែភាសា
១០-លោក	**គ្រាប សុធា**	ជំនួយការនាយកតំបន់

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបាន លទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៩៦ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត /០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
  បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា ១ : ផ្លាស់ និងតែងតាំងលោក **អ៊ឹម សុភិរ** បច្ចុប្បន្នប្រធាននាយកដ្ឋានអាមេរិក ជាប្រធាននាយកដ្ឋានផែនការនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៩៧ . អនក្រ . តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត /០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សំរេច

មាត្រា ១ : តែងតាំងលោក **សរ សម្បត្តិ** អតីតតំណាងអចិន្ត្រៃយ៍រង នៃស្ថានបេសកកម្មអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការសហប្រជាជាតិ ជាប្រធាននាយកដ្ឋានអាមេរិក នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៧៤៩ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ បក ចុះថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រង ការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងផែនការ ។

សម្រេច

មាត្រា១.- ត្រូវបានប្រគល់ភារកិច្ចជូនលោក **ម៉ន ម៉ុននិត្យ** អោយបំពេញមុខងារជានាយករងវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ មានឋានៈ**ស្មើអគ្គនាយករង** ។

មាត្រា២.- បទប្បញ្ញត្តិណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: [illegible]

អនុក្រឹត្យ
ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រង ការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនលោក **ទុំ សារាវុធ** អោយបំពេញមុខងារជាសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យស្វាយរៀង មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និង ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៖ ៩៧០ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យ លេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

សម្រេច

មាត្រា ១៖ ត្រូវបានប្រគល់ភារកិច្ចជូន លោកស្រី លួង ជល្លា ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ នៃក្រសួងអភិវឌ្ឍន៍ជនបទ ។

មាត្រា ២៖ បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៩០១ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសហមេត្រី

៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ជូនមន្ត្រី នៃអង្គការ អ៊ីយូអាសាក់ (EU/ASAC) ចំនួន ០៣រូប ដែលមានស្នាដៃល្អ ក្នុងកិច្ចសហប្រតិបត្តិការ ជួយទុកដាក់អាវុធជាតិផ្ទុះ ប្រកបដោយសុវត្ថិភាព នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោម :-

ក-មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ :

១-លោក ដេវីដ ឌី បៀ (**DAVID DE BEER**) ទីប្រឹក្សាពិសេសសហភាពអឺរ៉ុប និងជានាយកគំរោងជំនួយ អ៊ីយូអាសាក់ (**EU/ASAC**)

ខ-មេដាយសហមេត្រី ថ្នាក់ សេនា :

១-លោក អាឡាំង ប៉េរីហ្គោ (**ALAIN PERIGAUD**) នាយករងចាត់ចែងគំរោង អ៊ីយូអាសាក់ (**EU/ASAC**)

២-លោក អេដ្រៀន ស្ព្រែងមេយ័រ (**ADRIAN SPRANGEMEJER**) មន្ត្រីគំរោង អ៊ីយូអាសាក់ (**EU/ASAC**)

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:.....៨២.....អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ០៨រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ទិញដីធ្វើសាលារៀន ចំនួន០២ខ្នង ព្រមទាំងបានកសាងស្ពាន ចំនួន០១ នៅឃុំបានាវ ស្រុកឈូក ខេត្តកំពត ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមាសស្ថាបនាជាតិ :

១-ឧកញ៉ា **ស្វ សារិទ្ធ**	ទឹកប្រាក់ ចំនួន ១០.០០០ ដុល្លារ
២-Dr. CHEN BAO YUAN	ទឹកប្រាក់ ចំនួន ១០.០០០ ដុល្លារ
៣-Mr. CHENG CHUAN HSIN	ទឹកប្រាក់ ចំនួន ១០.០០០ ដុល្លារ
៤-Mr. ME YA-CHI	ទឹកប្រាក់ ចំនួន ១០.០០០ ដុល្លារ
៥-Mr. CHAN HSIU- CHING	ទឹកប្រាក់ ចំនួន ១០.០០០ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

១-ឧត្តមសេនីយ៍ត្រី **អ៊ុក គោសា**	នាយការិយាល័យអភិវឌ្ឍន៍	ទឹកប្រាក់ចំនួន ៦.០០០ ដុល្លារ
២-ឧត្តមសេនីយ៍ត្រី **សឺន ចំនួ**	លេខាផ្ទាល់ ឯកឧត្តម នាយឧត្តមសេនីយ៍ **មាស សុភា**	ទឹកប្រាក់ចំនួន ៥.០០០ ដុល្លារ
៣-Mr. LIM BOON KWANG	ប្រធានក្រុមហ៊ុនកាត់ដេរ យ៉ុងវ៉ា	ទឹកប្រាក់ចំនួន ៥.០០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ៨ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៩០៣ - អនក្រ - បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមុខតំណែងនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ម្រេ ច

មាត្រា ១ ..

ត្រូវបានតែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ទោ ឈឹម ជួន អត្តលេខ ០០១៦ ជាអនុប្រធានទី ១ នាយកដ្ឋានកណ្តាលមធ្យោបាយ នៃក្រសួងមហាផ្ទៃ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ ..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង - ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៩០៤ អនក្រ-បក

អនុក្រឹត្យ

ស្តីពី

ការអនុវត្តវិន័យនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត/០៧០៤/ ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/ រកម /០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ .-

ត្រូវបានអនុវត្តវិន័យចំពោះនាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃចំនួន ០២ នាក់ដូចខាងក្រោម :

១ - លោកវរសេនីយ៍ឯក **សុខ សុខណ្ណ** អត្តលេខ ០៦១៥ ដោយរូបភាពដកហូតឋានន្តរស័ក្តិ និងបណ្តេញចេញពីក្របខ័ណ្ឌនគរបាលជាតិ ។

មូលហេតុ : បានល្មើសវិន័យរបស់កងកំលាំងនគរបាលជាតិ ដោយយកតួនាទីសិទ្ធិអំណាច និង ភារកិច្ចរបស់ខ្លួនធ្វើមតិនិតក្នុងការក្លែងបន្លំឯកសារមន្ត្រីនគរបាលដែលបោះបង់ចោលការងារ ទៅជាមន្ត្រីនគរបាល - ទទួលមរណៈភាព ហើយបើកយកប្រាក់ឧបត្ថម្ភពីសមាគមមិត្តនគរបាលជាតិកម្ពុជា ។

២ - លោកវរសេនីយ៍ឯក **ដោក សារឡឹន** អត្តលេខ ០៦១៩ ដោយរូបភាពដកហូតឋានន្តរស័ក្តិ ។

មូលហេតុ : បានល្មើសវិន័យរបស់កងកំលាំងនគរបាលជាតិ ដោយយកភារកិច្ចរបស់ខ្លួន ឃុបឃិតគ្នាក្នុងការក្លែងបន្លំឯកសារមន្ត្រីនគរបាល ដែលបោះបង់ចោលការងារ ទៅជាមន្ត្រីនគរបាលទទួលមរណៈភាព ហើយបើកយកប្រាក់ឧបត្ថម្ភពីសមាគមមិត្តនគរបាលជាតិកម្ពុជា ។

មាត្រា ២ .-

លោក **ជៀត សារឿន** ត្រូវទទួលឋានន្តរស័ក្តិទៅតាមការសំរេចរបស់ក្រសួងមហាផ្ទៃ ។

មាត្រា ៣ .-

រាល់ការកំណត់ទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

__កន្លែងទទួល__
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៧០៥...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនលោក BAKU SAITO ជាវិចិត្រករថតរូប នៅប្រទេសជប៉ុន ដែលមានស្នាដៃល្អក្នុងការជួយជួសជុល កសាងសាលារៀន និងជួយផ្សព្វផ្សាយអំពីព្រះរាជាណាចក្រកម្ពុជា នៅប្រទេសជប៉ុន ប្រទេសបារាំង និងលើឆាកអន្តរជាតិ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥០៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តកំពង់ស្ពឺ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកស្រី **គ្រីស ឌីន** តំណាងអង្គការ***អង្គរបែលហ្វ្រិក*** ដែលបានឧបត្ថម្ភថវិកា ចំនួន ៣៩.៤៩៣ ដុល្លារអាមេរិក សំរាប់ជួយសាងសង់អគារសិក្សា ០២ខ្នង មាន០៨បន្ទប់ និងអគារកាត់ដេរ ០១ខ្នង មាន ០២បន្ទប់ បំពាក់ដោយសម្ភារៈគ្រប់គ្រាន់ នៅសាលាបឋមសិក្សា ពន្លឺកុលបុត្រ ឃុំព្រះនិព្វាន ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩០៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ១៩៩៤ ស្តីពីការបង្កើត និង ប្រើប្រាស់ប័ណ្ណស្ថាបនាជាតិ នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនអស់លោកសប្បុរសជន ចំនួន ៩៣ នាក់ ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ជួយកសាង សាកលវិទ្យាល័យស្វាយរៀង ដូចមានរាយនាមខាងក្រោមនេះ :

ក/ មេដាយមាសស្ថាបនាជាតិ

១-	លោកជំទាវ	ម៉ែន សំអន	ថវិកាចំនួន ១២,០០០ ដុល្លាអាមេរិក
២-	ឯកឧត្តម	គឹម ឆា	ថវិកាចំនួន ១០,០០០ ដុល្លាអាមេរិក
៣-	លោកឧកញ៉ា	តាន់ ស្រ៊ី	ថវិកាចំនួន ៤០,០០០ ដុល្លាអាមេរិក
៤-	លោក	ឃាំង ស៊ុយសាំង	ថវិកាចំនួន ១៥,០០០ ដុល្លាអាមេរិក
៥-	លោកឧកញ៉ា	គិត ម៉េង	ថវិកាចំនួន ៤០,០០០ ដុល្លាអាមេរិក
៦-	លោកឧកញ៉ា	ដួង ខៀវ	ថវិកាចំនួន ៣១,៨៥៣ ដុល្លាអាមេរិក
៧-	លោកប្រធានក្រុមហ៊ុន អាណាឌីយ៉ា		ថវិកាចំនួន ៣០,០០០ ដុល្លាអាមេរិក
៨-	លោកឧកញ៉ា	លី យ៉ុងផាត់	ថវិកាចំនួន ៣០,០០០ ដុល្លាអាមេរិក
៩-	កាស៊ីណូ ធាវិតម៉ុកបាយ		ថវិកាចំនួន ២០,០០០ ដុល្លាអាមេរិក
១០-	លោកជំទាវ	ស៊ុយ សុផាន់	ថវិកាចំនួន ២០,០០០ ដុល្លាអាមេរិក
១១-	លោកស្រី	សាត ណាវី	ថវិកាចំនួន ១៥,០០០ ដុល្លាអាមេរិក
១២-	លោកស្រី	សោម សុផល	ថវិកាចំនួន ១៥,០០០ ដុល្លាអាមេរិក
